មន្ទីរអប់រំយុវជន និងកីឡា **តារាងស្ថិតិសរុបកូនឈើដាំដុះក្នុងសាលារៀនចំណេះទូទៅ**

ខេត្ត_ក្រុង .......... **ក្នុងឆមាសទី .... ( ១៩៩ .... ១៩៩ ... )**

ឧទាហរណ៍ :

* * * *

| ល.រ | ឈ្មោះដើមឈើ | បឋមសិក្សា | | អនុវិទ្យាល័យ | | វិទ្យាល័យ | | សរុប | ដាំថ្មី | រៀ |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ដាំថ្មី | សរុប | ដាំថ្មី | សរុប | ដាំថ្មី | | | |
| ១ | ដើមដូង | ៩០០ដ | ១០០ដ | ៥០០ដ | ៥០ដ | ៣០០ដ | ៣០ដ | ១៧០០ដ | ១៨០ដ | |
| ២ | ដើមទឹកដោះ | ៨០០ដ | ៥០ដ | ៤៥០ដ | ៤០ដ | ២០០ដ | ២៥ដ | ១៤៥០ដ | ១១៥ដ | |
| ៣ | ដើមស្វាយ | ២០០ដ | ៤០ដ | ៣០០ដ | ៥០ដ | ១៥០ដ | ៣០ដ | ៦៥០ដ | ១២០ដ | |
| សរុបដើមឈើហូបផ្លែ | | ១៩០០ដ | ១៩០ដ | ១២៥០ដ | ១៤០ដ | ៦៥០ដ | ៨៥ដ | ៣៨០០ដ | ៤១៥ដ | |
| ១ | ដើមគគីរ | ៥០០ដ | ១០០ដ | ៧០០ដ | ២០០ដ | ៣០០ដ | ១០០ដ | ១៥០០ដ | ៤០០ដ | |
| ២ | ដើមប្រេងខ្យល់ | ១៥០០ដ | ៣០០ដ | ២០០ដ | ៥០ដ | ៥០០ដ | ៤០០ដ | ២២០០ដ | ៧៥០ដ | |
| សរុបដើមឈើយកម្លប់ | | ២០០០ដ | ៤០០ដ | ៩០០ដ | ២៥០ដ | ៨០០ដ | ៥០០ដ | ៣៧០០ដ | ១១៥០ដ | |

* កំណត់សំគាល់ : –បញ្ជាក់ដើមឈើហូបផ្លែមុន (ក្នុងតារាង)

–សរុប : កូនឈើដាំពីមុនមក + កូនឈើទើបដាំថ្មី

ឧ. សរុប : ដូង : ៩០០ដ ក្នុងនោះដាំថ្មីក្នុងឆមាស ១០០ដ។

បានឃើញ និងឯកភាព ធ្វើនៅថ្ងៃទី ................

ប្រធានមន្ទីរអប់រំយុវជន និង កីឡា អ្នករាយការណ៍

* * *

## ៤ - ទីស្ដីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០៥៥ បឌ**

**ស្ដីពីថ្លៃប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងប្រទេស និង អន្តរជាតិ**

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៤៩៦/២០ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-៣-៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ

**សំរេច**

**ប្រការ ១** : កំណត់ថ្លៃប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងប្រទេស និង អន្តរជាតិ ដូចមានឧបសម្ព័ន្ធទី១ ដល់ ឧបសម្ព័ន្ធទី៦ ភ្ជាប់នឹងសេចក្តីប្រកាសនេះ ។

**ប្រការ ២** : ប្រកាសលេខ ០៣៨ បទ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥និងបន្ថែមឧបសម្ព័ន្ធទី ៦ ស្តីពីការផាកពិន័យលេខ ២៧៤៨ បទ ចុះថ្ងៃទី ០៥-១០-៩៥ រួមទាំងប្រកាសទាំងឡាយណាដែលមាន ពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ទុកជានិរាករណ៍ ។

**ប្រការ ៣** : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋាន ផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង នាយកដ្ឋានប្រៃសណីយ៍ត្រូវទទួល បន្ទុកអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋលេខាធិការ**

**ហត្ថលេខា និង ត្រា**

**សូ ឃុន**

* * *

<u>ឧបសម្ព័ន្ធទី ១</u> : ថ្លៃប្រើប្រាស់រលករអាកាសវិទ្យុ

សំគាល់ : - រយៈពេលកំណត់នៃអាជ្ញាប័ណ្ណមានមួយឆមាស ឬ មួយឆ្នាំ ក្នុងករណីអាជ្ញាប័ណ្ណមានរយៈពេលមួយឆមាស តម្លៃអាជ្ញាប័ណ្ណស្មើ នឹង ពាក់កណ្តាលនៃតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

- ការសុំប្រើប្រាស់បន្តដោយគ្មានប្រការណាមួយប្រែប្រួលនៅក្នុងអាជ្ញាប័ណ្ណចាស់ គឺត្រូវបង់តែតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសំរាប់អាជ្ញាប័ណ្ណថ្មី ។

- អ្នកកោសលុប ឬ ក្លែងបន្លំដោយប្រការណាមួយនៅលើអាជ្ញាប័ណ្ណត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

- អានុភាពផ្សាយគិតតាមអានុភាពអតិបរិមានៃបរិក្ខារ

| | |
|---|---|
| ១– ថ្លៃផ្តល់វិញ្ញាបនប័ត្រ | $ |
| – ការីវិទ្យុ | ១៥ |
| – វិទ្យុអាម៉ាទ័រ ថ្នាក់ទី១ | ១៥ |
| – វិទ្យុអាម៉ាទ័រ ថ្នាក់ទី២ | ១២ |
| – វិទ្យុអាម៉ាទ័រ ថ្នាក់ទី៣ | ១០ |
| ២– វិទ្យុប្រភេទ HF | $ |
| ក-/ វិទ្យុប្រភេទ HF ចល័ត | |
| – ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ | ៥ |
| – ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើនាវា | ១៥ |
| – ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើដីគោក | ១០ |
| – តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង | |
| ចំពោះអានុភាព X watt និងបន្ទារប្រេកង់ Y KHz | ២០+១.៥ X +២ Y |
| ខ-/ វិទ្យុប្រភេទ HF អចល័ត | $ |
| – ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ | ៥ |
| – ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ១០ |
| – តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង | |
| • ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz | ២០+០.៨ X +២ Y |
| ៣– វិទ្យុប្រភេទ VHF | $ |
| ក-/ វិទ្យុប្រភេទ VHF ចល័ត | |
| – ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ | ៤ |
| – ការពិនិត្យថបនភ័ណ្ឌមួយគ្រឿង ៗ មុនពេលតំលើង : | |
| ចំពោះវិទ្យុទាក់ទងតូចៗ កាន់ជាប់ នឹង ដៃ (walkie talkic ) | ៥ |

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ៨

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១០

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០+ ០.៦X +០.៤Y
$

ខ-/ វិទ្យុប្រភេទ VHF អចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៤

- ការពិនិត្យបទភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេង Y KHz ១០+០.៤X+០.៤Y
$

៤- វិទ្យុប្រភេទ UHF និង SHF

៤.១ - វិទ្យុចល័តតូចៗកាន់ជាប់ នឹង ដៃ ( walkie Talkie )

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៤

- ការពិនិត្យបទភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង : ៥

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០+០.៧X+ ០.៤Y

៤.២ - វិទ្យុប្រភេទអចល័ត

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ៨

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១០

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

៤.២.១ ហ្វ្រេកង់ទាបជាង ១ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០+៣X +០.៨Y

៤.២.២ ហ្វ្រេកង់ពី ១ - ៣ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz ២០+៤X + ០.៧Y

៤.២.៣ ហ្វ្រេកង់ចន្លោះពី ៣ ៨ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz ២០+៥X + ០.៦Y

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz ២០+ ៦X + ០.៥Y

៤.២.៤ ហ្វ្រេកង់ពី ៨ GHz ឡើងទៅ

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz ២០+៦X+ 0.៥ Y

៤.៣ វិទ្យុប្រភេទចល័ត

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ៨

ចំពោះទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១០

៤.៣.១ ហ្វ្រេកង់ទាបជាង 1 GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០+ ៤ X + ១ Y

៤.៣.២ ហ្វ្រេកង់ពី ១.៣ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០ + ៥ X + 0.៩ Y

៤.៣.៣ ហ្វ្រេកង់ចន្លោះពី ៣.៨ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០ + ៦ X + 0.៨ Y

៤.៣.៤ ហ្វ្រេកង់ពី ៨ CHz ឡើងទៅ

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០ + ៧ X + 0.៧ Y

៥– វិទ្យុទាក់ទងអន្តរជាតិ ( ក្នុងករណីមានការអនុញ្ញាតពិសេស ) $

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ១០

– ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ២០

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង ២០ + 0.៨ X + ២ Y

៦– វិទ្យុផ្សាយសំលេង $

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៣០

– ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០

ក-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ HF AM :

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០០ + 0.0៥ X + ២0Y

ខ-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ VHF FM :

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០០ + 0.0៥ X + ២Y

៧– ទូរទស្សន៍ $

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៣០

– ការពិនិត្យឋបនភ័ណ្ឌ មុនពេលតំលើង ៥០

ក-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ VHF :

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz : ១០០ + 0.0៥ X+ 0.0៥ Y

ខ-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ UHF

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០០ + 0.0៥ X + 0.0៥ Y

៨– វិទ្យុអាម៉ាទ័រ

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០
- ការពិនិត្យឋបនភ័ណ្ឌ មុនពេលតំលើង ៥
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ២៥

៩–អ៊ិនម៉ាសាត

ក- អ៊ិនម៉ាសាតគ្រប់ប្រភេទ ប្រើប្រាស់លើដីគោក

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០០
- តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិនម៉ាសាតលើដី + ៣០%
- ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត១គ្រឿង ១.០០០

ខ– អ៊ិនម៉ាសាតប្រភេទ A . B និង C នៅលើនាវា

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ៣០០

ចំពោះអ៊ិនម៉ាសាតប្រភេទ A.B និង C នៅលើនាវា អតិថិជនអាចជ្រើសរើសយកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ អង្គការណាមួយក៏បាន ធ្វើជាអាជ្ញាធរទូទាត់ (Accounting Authority ) សំរាប់ទូទាត់តម្លៃជាមួយស្ថានីយ៍អ៊ិនម៉ាសាតលើដី ។

ប្រសិនបើជ្រើសរើសយកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជាអាជ្ញាធរសំរាប់ទូទាត់តម្លៃ :

- តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិនម៉ាសាតលើដី + ១០%
- ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត ១ គ្រឿង ៣.០០០

គ- ចំពោះអ៊ិនម៉ាសាត M ដែលចុះឈ្មោះនៅបរទេស

ហើយនាំចូលមកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា :

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៣០
- តម្លៃអាជ្ញាប័ណ្ណ :

តិចជាង ២០ ថ្ងៃ ២៥/ថ្ងៃ

| | |
|---|---|
| ពី ២០- ២៥ ថ្ងៃ | ៥០០ |
| លើសពី ២៥ ថ្ងៃ | ២០/ថ្ងៃ |

ឧបសម្ព័ន្ធទី ២ : ថ្លៃប្រើប្រាស់បរិបថទិន្នន័យអន្តរជាតិ

ថ្លៃខាងក្រោមនេះមិនរាប់បញ្ចូលថ្លៃនៃប្រព័ន្ធទិន្នន័យក្នុងប្រទេសឡើយ ។

១- **បរិបថអក្ខរលេខ** ( Digital circuits )

| ល្បឿន<br>KBit/s | ថ្លៃក្នុង១ខែ<br>$ | ថ្លៃស្ថាបនា<br>$ |
|---|---|---|
| ២.៤ | ១.៥០០ | ៨០០ |
| ៤.៨ | ២.៥០០ | ១.០០០ |
| ៩.៦ | ៣.៣០០ | ១.៣០០ |
| ១៩.២ | ៤.០០០ | ១.៦០០ |
| ៤៨ឬ៥៦ឬ៦៤ | ៦.២០០ | ២.០០០ |
| ១២៨ | ៩.៨០០ | ២.៤០០ |
| ១៩២ | ១៣.៥០០ | ២.៨០០ |
| ២៥៦ | ១៦.២០០ | ៣.០០០ |
| ៣៨៤ | ២២.២០០ | ៣.៥០០ |
| ៥១២ | ២៨.៤០០ | ៤.០០០ |
| ៧៦៨ | ៤០.០០០ | ៤.៥០០ |
| ១០២៤ | ៤៨.៧០០ | ៥.០០០ |
| ១៥៤៤ | ៥៩.០០០ | ៦.០០០ |
| ២០៤៨ | ៦៦.០០០ | ៦.[illegible] |

២- **បរិបថអាណាឡូក** ( Analogue circuits )

| ប្រទេស | ថ្លៃក្នុង១ខែ<br>$ | ថ្លៃស្ថាបនា<br>$ |
|---|---|---|
| ឡាវ ថៃ និង | | |
| វៀតណាម | ៤.០០០ | ១.៦០០ |
| ប្រទេសដទៃ | ៥.០០០ | ១.៦០០ |

**ឧបសម្ព័ន្ធទី៣ : ថ្លៃបញ្ជូនរូបភាពទៅអន្តរជាតិ**

ថ្លៃត្រឹមពាក់កណ្តាលផ្លូវ ( គឺពីប្រទេសកម្ពុជាទៅផ្កាយរណប )

| | |
|---|---|
| ១– ការបញ្ជូនតាមប្រព័ន្ធ អ៊ិនតែលសាត ( Tntelsat ) | $ |
| ១០–នាទីដំបូង | ៦០០ |
| រាល់មួយនាទីក្រោយ | ៣០ |
| ១– ការបញ្ជូនតាមប្រព័ន្ធ អ៊ិនទើស្ពុតនិក ( Tnterspurnik ) | $ |
| ១០–នាទីដំបូង | ៤៤០ |
| រាល់មួយនាទីក្រោយ | ១២ |

**ឧបសម្ព័ន្ធទី៤ : ថ្លៃប្រើប្រាស់ទូរពុម្ព**

| | |
|---|---|
| | $ |
| ការស្ថាបនាខ្សែ | ៣៨០ |
| ការជួលជាប្រចាំខែ | ៨០ |
| ថ្លៃប្រើប្រាស់ក្នុងប្រទេស | $ ( ក្នុង ១នាទី ) |
| | ០.៣០ |
| ថ្លៃប្រើប្រាស់ទៅអន្តរជាតិ | $ ( ក្នុង ១ នាទី ) |
| ប្រទេសលាវ ថៃ និង វៀតណាម | ៣.៨០ |
| ប្រទេសអាស៊ីដទៃ | ៤.០០ |
| ប្រទេសដទៃ | ៤.៥០ |

**ឧបសម្ព័ន្ធទី៥ : ថ្លៃសុំច្បាប់ប្រើបរិធានទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា (Type Approval )**

| | |
|---|---|
| | $ |
| ទូរស័ព្ទធម្មតា | ១.០០០ |
| ទូរស័ព្ទចល័ត | ៣.០០០ |
| ផេចជិញ | ១.០០០ |
| ទូរសារ | ៣.០០០ |
| បមាណី ( PABX ) | ៣.០០០ |
| បរិក្ខារវិទ្យុ | ២.០០០ |
| ការសុំបង្កើតភ្នាក់ងារនាំបរិធានទូរគមនាគមន៍ចូលប្រទេសកម្ពុជា | ១.០០០ |

ថ្លៃប្រចាំឆ្នាំ ១.០០

ឧបសម្ព័ន្ធទី៦ : ការផាកពិន័យ

សំគាល់ : ប្រាក់ពិន័យពុំមែនជាប្រាក់សំរាប់ទូទាត់តំម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

៦.១ ការប្រើប្រាស់បរិក្ខារវិទ្យុមួយគ្រឿងទោះចល័តក្តី អចល័តក្តី ហើយគ្មានអាជ្ញាប័ណ្ណប្រាក់ពិន័យស្មើនឹងតំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារវិទ្យុនោះគុណនឹង ៥ ។

៦.២ ការផ្លាស់ប្តូររលកអាកាសវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណ នឹង ៤ ។

៦.៣ ការផ្លាស់ប្តូរឋបនភ័ណ្ឌវិទ្យុ ឬ ទីតាំងឋបនភ័ណ្ឌវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹងតំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខានោះគុណនឹង៣។

៦.៤ ការប្រើប្រាស់អាជ្ញាប័ណ្ណហួសពេលកំណត់ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃ បរិក្ខារនោះគុណ នឹង ២ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៦

## ប្រកាស

### លេខ០៥៦ បឌ.ប្រក

### ស្តីពីការផ្លាស់ប្តូរតួនាទី ភារកិច្ច មន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទ សម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦.២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍